# ព្រឹត្តិបត្រ អ្នកឃ្លាំមើល

ខុមហ្វ្រែល COMFREL

## NEAK KHLOAM MEUL - OBSERVER BULLETIN

លេខ៥១ ឆ្នាំទី១៧ ចេញផ្សាយថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤





=> សេចក្តីថ្លែងហេតុ សំណើរវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ (ទំព័រ១)

=> របាយការណ៍ប្រចាំឆ្នាំស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងការកែទម្រង់ (ទំព័រ ៨)

=> កិច្ចពិភាក្សាតុមូលស្តីពី កំណែទម្រង់ការបោះឆ្នោត និងសកម្មភាពផ្សព្វផ្សាយទៅសាធារណៈជន (ទំព័រ ៩)

=> សិក្ខាសាលាបង្ហាញអំពី "សេចក្តីស្នើវិសោធនកម្មក្របខណ្ឌច្បាប់ទាក់ទងស្ថាប័នគ្រប់គ្រងការបោះឆ្នោត យន្តការដោះស្រាយវិវាទបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត" (ទំព័រ ១១)

=> ការចេញផ្សាយសៀវភៅរដ្ឋសភា ជីវប្រវត្តិសង្ខេបតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៥ និងដំណើរវេទិកាសួរអ្នកតំណាង (ទំព័រ ១២)

=> សេចក្តីប្រកាសព័ត៌មាន អត្ថបទស្តីពីការរំលោភច្បាប់ និងការជ្រៀតជ្រែកនយោបាយ ក្នុងដំណើរការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ អាណត្តិទី២ (ទំព័រ ១៦)

=> ព័ត៌មានផ្សេងៗ និងកំសាន្ត (ទំព័រ ២១)

# សេចក្តីថ្លែងហេតុ ដោយសង្ខេប
# ស្តីពី សំណើរវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

សំណើរ នេះមានគោលបំណងផ្តល់ឯកសារជាក់លាក់មួយស្តីពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដែលផ្តោតយកចិត្តទុកដាក់លើកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត ការផ្លាស់ប្តូរប្រព័ន្ធចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត ការកែលម្អប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត និងការពង្រឹងយន្តការដោះស្រាយទំនាស់ និងវិវាទបោះឆ្នោត។

សំណើរជាក់លាក់នេះ អាចជាជំនួយដល់គណៈកម្មការកែទម្រង់ការបោះឆ្នោតនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ រួមទាំងអ្នកសម្រេចចិត្តខាងបច្ចេកទេស និងខាងនយោបាយ នៃគណបក្សទាំងពីរ ដើម្បីពិនិត្យឡើងវិញ និងធ្វើសេចក្តីសម្រេចចិត្តក្នុងរយៈពេលខ្លីមួយ។

ជាការពិតសំណើរនេះបានដាក់តែចំណុចអាទិភាពសំខាន់ៗតែប៉ុណ្ណោះ ដោយមិនទាន់បានគ្រប់ដណ្តប់លើ ចំណុចខ្វះខាតជាច្រើនទៀត ដែលត្រូវកែទម្រង់។ សំណើរនេះបានមកពីការរកឃើញជាច្រើនអាណត្តិនៃកាបោះឆ្នោត និងចេញពីអនុសាសន៍របស់អ្នកសង្កេតការណ៍ឯករាជ្យជាតិ អន្តរជាតិ អង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធការបោះឆ្នោតដោយផ្ទាល់មួយចំនួន ដូចជាគណបក្សនយោបាយ និងអង្គការសង្គមស៊ីវិលឯករាជ្យ។ អនុសាសន៍ទាំងនេះក៏ត្រូវបានទទួលយកទៅពិភាក្សាជាមួយប្រជាពលរដ្ឋ អ្នកឯកទេសបោះឆ្នោតជាតិ និងអន្តរជាតិ រួមទាំងអ្នកច្បាប់ មួយចំនួនផងដែរ។

សំណើរនេះត្រូវបានសិក្សាផ្ទៀងផ្ទាត់ជាមួយគោលការណ៍ស្តីពីការរៀបចំ និងចាត់ចែង ការបោះឆ្នោតមួយសេរី យុត្តិធម៌ សុចរិតភាព និងតាមគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។ គោលការណ៍និងអនុសាសន៍របស់អន្តរជាតិ និងអង្គការសហប្រជាជាតិ សំខាន់មានចែងនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជាជំពូកទី៣ ទី៤ និងទី៧ និងកត្តិការសញ្ញាស្តីពី សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ ទាក់ទិនសេរីភាពខាងនយោបាយ និងសិទ្ធិបោះឆ្នោត និងការបកស្រាយកត្តិការសញ្ញានេះ នៅក្នុងមាត្រា ២៥ ទាក់ទិនការបង្កើតស្ថាប័នរៀបចំការបោះឆ្នោត "ឯករាជ្យ" និងកាតព្វកិច្ចរបស់រដ្ឋក្នុងការធានាប្រសិទ្ធិភាពនៃការចុះឈ្មោះបោះឆ្នោត។

ស្ថាប័នគ្រប់គ្រងការបោះឆ្នោត គ.ជ.ប គួរត្រូវបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញ។ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដាក់បញ្ចូលគោលការណ៍ជ្រើសរើសសមាសភាព អាណត្តិ និងតួនាទី សិទ្ធិអំណាចសំខាន់ៗស្ថាប័នដោះស្រាយវិវាទបោះឆ្នោតក្រុមប្រឹក្សាធម្មនុញ្ញ។

នេះមិនមែនជាបញ្ហាចំឡែកនៅកម្ពុជាទេ ប្រទេសអាស៊ីជាច្រើនដូចជា ប្រទេសថៃ ឥណ្ឌូនេស៊ី កូរ៉េខាងត្បូងក៏បានដាក់ស្ថាប័នរៀបចំការបោះឆ្នោតនៅក្នុងរដ្ឋធម្មនុញ្ញ ដោយរួមបញ្ចូលកំណត់តួនាទី សិទ្ធិ អំណាច និងការជ្រើសរើសសមាសភាពស្ថាប័ននេះជាសាធារណៈ ហើយប្រទេសដែលមានបរិបទនយោបាយស្មុគស្មាញ បានប្រើប្រាស់រូបមន្តមតិភាគច្រើនពីរភាគបី អនុម័តគាំទ្រសមាសភាពស្ថាប័នរៀបចំការបោះឆ្នោតដូចជាប្រទេសនីហ្សេរីយ៉ា ទុយនេស៊ី យេមេន ។ល។

អនុសាសន៍សំខាន់របស់បេសកម្មសង្កេតការណ៍បោះឆ្នោត នៃសភាពអឺរ៉ុបនៅកម្ពុជា២០០៨ (EUEOM 2008) គ.ជ.ប ត្រូវតែជាស្ថាប័នឯករាជ្យនៅគ្រប់លំដាប់ថ្នាក់ ហើយការជ្រើសរើសសមាជិក គ.ជ.បត្រូវបានអនុវត្តដោយការយល់ព្រមជាឯកច្ឆ័នពីគណបក្សនយោបាយមានអាសនៈនៅក្នុងសភា។អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិនៅកម្ពុជា លោក សូរិយា ប្រាសាទ ស៊ូប៊ែឌី (Surya P. Subedi) បានផ្តល់អនុសាសន៍នៅឆ្នាំ២០១២ ស្តីពីការជ្រើសរើសសមាសភាព គ.ជ.ប ស្រដៀងគ្នានឹងអនុសាសន៍របស់អ្នកសង្កេតការណ៍សហភាពអឺរ៉ុប (EUEOM2008) ផងដែរ។ បេសកម្ម EUEOM 2008 និងអ្នករាយការណ៍ពិសេសបានសង្កត់ធ្ងន់ចំពោះប្រព័ន្ធផ្សព្វផ្សាយត្រូវផ្តល់ឲ្យគណបក្សនយោបាយប្រកួតប្រជែងតាមគោលការណ៍សមធម៌ និងស្មើគ្នា (Fair and Equal Access)។ ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃចំណុចសំខាន់ៗ នៃការកែទម្រង់ការបោះឆ្នោតៈ

## ១. ឯករាជ្យភាពរបស់ស្ថាប័នគ្រប់គ្រងការបោះឆ្នោត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបន្ថែមជំពូកថ្មីមួយ(ជាជំពូកទី១៥) ស្តីអំពីគណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត (គ.ជ.ប) ដើម្បីកំណត់អាណត្តិ ពង្រឹងឯករាជ្យភាព បង្កើតតម្លាភាព និងការទុកចិត្តលើការជ្រើសរើសសមាសភាព និងបន្ថែម សិទ្ធិ អំណាច និងការទទួល ខុសត្រូវ។ គ.ជ.ប មានសមត្ថកិច្ចធានា ដំណើរការបោះឆ្នោតប្រកបដោយសេរី យុត្តិធម៌ និងសុចរិតភាព និងគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស។ គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោត (គ.ជ.ប) មិនត្រឹមតែមានសមត្ថកិច្ចរៀបចំការបោះឆ្នោតប៉ុណ្ណោះទេ ប៉ុន្តែគណៈកម្មាធិការនេះក៏ធ្វើការចុះឈ្មោះបោះឆ្នោត ការអប់រំដល់អ្នកបោះឆ្នោត និងការកែលម្អរច្បាប់ និងប្រព័ន្ធបោះឆ្នោត នៅចន្លោះពេលបោះឆ្នោតផងដែរ។
- អាណត្តិ ច្បាស់លាស់ និងអភ័យឯកសិទ្ធិត្រូវបានកំណត់តាមច្បាប់។ សមាជិក គ.ជ.ប មានចំនួនយ៉ាងតិច៥នាក់ និងយ៉ាងច្រើនចំនួន៩នាក់ ដែលមានអាណត្តិយ៉ាងច្រើនប្រាំឆ្នាំ។ សមាជិក គ.ជ.ប មានអភ័យឯកសិទ្ធិដូចសភា។ គ.ជ.ប ត្រូវមានកញ្ចប់ថវិការជាតិស្វយ័ត អនុម័តដោយរដ្ឋសភា។ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ទាំងអស់ ត្រូវបានតែងតាំងដោយព្រះរាជ្យក្រឹត្យ ក្រោយពីបានទទួលការយល់ព្រមពីសភាចំនួនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូលតាមសំណើរបស់គណៈកម្មការជ្រើសរើស។
- ដើម្បីតម្លាភាព និងការបើកចំហរការជ្រើសរើស ស្ថាប័នជ្រើសរើសបេក្ខជនសមាជិកគ.ជ.ប ត្រូវបានផ្លាស់ប្តូរពីក្រសួងមហាផ្ទៃ និងពីគណៈរដ្ឋមន្ត្រីមកឲ្យ "គណៈកម្មការជ្រើសរើសមួយ"។ ព្រោះកន្លងមក ក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រីមានគណបក្សចំរុះរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច រហូតដល់មានសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ក្រោយពីផ្លាស់រូបមន្តអនុមត្តិទុកចិត្តលើរដ្ឋាភិបាលពីមតិភាគច្រើន ពីរភាគបី មកមតិភាគច្រើនដាច់ខាត ៥០%+១ នៃសមាជិករដ្ឋសភាទាំងមូលដែលនាំឲ្យគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃត្រូវបានដឹកនាំ ដោយគណបក្សតែមួយ។ ដូចនេះវាបានបាត់ប្រព័ន្ធត្រួតពិនិត្យគ្នា នៃគណបក្សសំខាន់ៗនៅក្នុងរដ្ឋាភិបាលដើម្បីជ្រើសរើសបេក្ខជន គ.ជ.ប។ ដូចនេះ គណៈកម្មការជ្រើសរើស ត្រូវមានសមាសភាពចំរុះមកពីតំណាង

(ត)ក្រុមគណបក្សក្នុងរដ្ឋាភិបាល ក្រុមគណបក្សក្រៅរដ្ឋាភិបាល តំណាងអង្គការសង្គមស៊ីវិល និងតំណាងព្រះមហាក្សត្រ។ គណកម្មការជ្រើសរើសនេះ មានគោលការណ៍ជ្រើសរើសបេក្ខជនជាសាធារណៈ និងចម្រាញ់បេក្ខជនដោយមានការចូលរួមផ្តល់យោបល់ពីសាធារណៈជន ចំពោះបេក្ខជនសមាជិក គ.ជ.ប រួមទាំង បេក្ខជនសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់រាជធានី ខេត្ត ឃុំ សង្កាត់ និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។ គណៈកម្មការជ្រើសរើសនេះត្រូវចម្រាញ់យកបេក្ខជនជាបុរស និងស្ត្រី។ សមាជិក គ.ជ.ប ឬសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់មិនត្រូវធ្វើជាមន្ត្រីនៃគណបក្សនយោបាយណាមួយបានឡើយក្នុងរយៈពេលពីរឆ្នាំគិតពីថ្ងៃចប់អាណត្តិ។

- គណៈកម្មាធិការជាតិសម្រាប់ការបោះឆ្នោតត្រូវមានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវបន្ថែមក្នុងការចេញបទបញ្ជាហាមឃាត់ និងលុបចោលការសម្រេចឬសកម្មភាពរបស់រាជរដ្ឋាភិបាល និងមន្ត្រីនយោបាយផ្សេងទៀត ដែលប៉ះពាល់ជាអវិជ្ជមានលើដំណើរការការបោះឆ្នោតដោយសេរី យុត្តិធម៌ និងស្មើភាព។ គណៈកម្មាធិការនេះត្រូវផ្តល់សុពលភាពបេក្ខជនជាប់ឆ្នោតទៅជាតំណាងរាស្ត្រ ដោយរៀបចំបញ្ជីតំណាងរាស្ត្រយ៉ាងតិចចំនួន១២០រូបផ្ញើរថ្វាយព្រះមហាក្សត្រ។
- ដើម្បីបន្ថែមការទុកចិត្ត និងតម្លាភាពក្នុងដំណើរបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងចំណោមសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោត ត្រូវមានសមាជិកចំនួនពីរនាក់មកពីក្រុមគណបក្សនយោបាយ(ក្រុមគណបក្សនយោបាយកាន់រដ្ឋាភិបាល និងគណបក្សនយោបាយក្រៅរដ្ឋាភិបាល)ដែលមានភារកិច្ចផ្ទៀងផ្ទាត់ឈ្មោះ ទិន្នន័យនៅក្នុងបណ្ណបោះឆ្នោត ជាមួយនឹងទិន្នន័យបញ្ជីឈ្មោះបោះឆ្នោត និងឈរផ្ទៀងផ្ទាត់ទៅលើដំណើរកាប្រកាសលទ្ធផលសន្លឹកឆ្នោត។
- ច្បាប់បោះឆ្នោតត្រូវបញ្ញត្តិស្តីពីកាតព្វកិច្ច កិច្ចសហការណ៍របស់ គ.ជ.ប ជាមួយនឹងតំណាងគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សង្កេតការណ៍បោះឆ្នោត និងការបើកចំហរទិន្នន័យដែលអាចវិភាគបានដោយប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្តនៃទិន្នន័យ(កុំព្យូទ័រ) រួមមានបញ្ជីឈ្មោះបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ពាក្យបណ្តឹង របាយការណ៍ហិរញ្ញវត្ថុគណបក្សនយោបាយនៅពេលឃោសនាបោះឆ្នោត និងឯកសារបោះឆ្នោតផ្សេងៗទៀត ។

## ២.ការធានាសិទ្ធិបោះឆ្នោតតាមរយៈការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវបានផ្លាស់ប្តូរប្រព័ន្ធ និងស្ថាប័នអនុវត្ត ដើម្បីពង្រឹងការទទួលខុសត្រូវ និងបង្កើនតម្លាភាពដូចខាងក្រោម៖

- ស្មៀនឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ (កបស/យ) ត្រូវបានប្តូរទៅឲ្យលេខាធិការរាជធានី និងខេត្តរៀបចំការបោះឆ្នោត លធ/ខប ឬ/និង គណៈកម្មការឃុំសង្កាត់រៀបចំការបោះឆ្នោត គឃ/សប ដែលទទួលខុសត្រូវក្នុងការអនុវត្តការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត។ បញ្ជីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ត្រូវកត់ចូលក្នុងសៀវភៅបញ្ជី ឬប្រព័ន្ធទិន្នន័យមួយ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅលេខាធិការដ្ឋាន (លធ/ខប)។ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតត្រូវប្រតិបត្តិទៅតាម

ប្រព្រឹត្តកម្មស្វ័យប្រវត្តនៃទិន្នន័យ(កុំព្យូទ័រ) ដោយបញ្ចូលទិន្នន័យសំខាន់ៗបន្ថែមរួមមាន រូបថត ដែលត្រូវថតផ្ទាល់នៅកន្លែងចុះឈ្មោះបោះឆ្នោត និងទិន្នន័យជីវសាស្ត្រជាមួយស្នាមមេដៃស្តាំ (សម្រាប់ជនពិការមេដៃ ត្រូវមាននីតិវិធីដាច់ដោយឡែក) ។

- លធ/ខប ត្រូវធ្វើការចុះឈ្មោះបោះឆ្នោតជាអចិន្ត្រៃយ៍។ ចំណែក គឃ/សប ត្រូវធ្វើការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំក្នុងរយៈពេលកំណត់មួយ។ គ.ជ.ប អាចបង្កើតក្រុមចុះឈ្មោះបោះឆ្នោតពិសេស ដល់ក្រុមគោលដៅពិសេសមួយចំនួន។ ក្រុមគោលដៅពិសេសមានក្រុមពិរុទ្ធជនដែលជាប់នៅក្នុងមន្ទីរឃុំឃាំង កម្មករចំណាកស្រុករស់នៅក្រៅប្រទេស ប្រជាពលរដ្ឋខ្មែររស់នៅប្រទេសក្រៅ ក្រុម អ្នកជម្ងឺដែលសម្រាកព្យាបាលនៅមន្ទីពេទ្យ និងក្រុមមួយចំនួន ទៀតតាមការចាំបាច់។
- ដើម្បីជំនួសបណ្ណព័ត៌មានអ្នកបោះឆ្នោត លិខិតបញ្ជាក់អត្តសញ្ញាណបម្រើអោយការបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការបោះឆ្នោតផ្សេងទៀត អ្នកចុះឈ្មោះបោះឆ្នោតនឹងទទួលបានប័ណ្ណអ្នកបោះឆ្នោតបន្ទាប់ពីបញ្ជីឈ្មោះបោះឆ្នោតត្រូវបានផ្តល់សុពលភាពដោយ គ.ជ.ប។ អ្នកបោះឆ្នោតត្រូវបានលើកទឹកចិត្តអោយធ្វើការផ្លាស់ប្តូររូបថតជារៀងរាល់ម្ភៃឆ្នាំម្តងនៅក្នុងបញ្ជីបោះឆ្នោត និងប័ណ្ណអ្នកបោះឆ្នោត។ ក្នុងករណីដែលឯកសារខាងលើមិនអាចបញ្ជាក់អំពីលក្ខខណ្ឌនៃការស្នាក់នៅបានទេ ប្រជាពលរដ្ឋត្រូវនាំអ្នកធានាអះអាងពីរ(២)រូបដែលមានសិទ្ធិបោះឆ្នោត និងមានអាស័យដ្ឋានពិតប្រាកដនៅក្នុងឃុំ សង្កាត់នោះទៅបំពេញបែបបទចំពោះមុខ លធ/ខប ឬ គឃ/សប ដោយបញ្ជាក់ថាអ្នកសុំចុះឈ្មោះនោះពិតជារស់នៅក្នុងឃុំសង្កាត់នោះប្រាកដមែន។
- គណបក្សនយោបាយ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីសង្កេតការបោះឆ្នោត មានសិទ្ធិទទួលបានបញ្ជីបោះឆ្នោតដំបូង ថតចម្លង ឬ/និងទិន្នន័យ ដែលអាចវិភាគបានដោយប្រព័ន្ធប្រព្រឹត្តិកម្មស្វ័យប្រវត្ត(កុំព្យូទ័រ)បាន។ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវសហការជាមួយគណបក្សនយោបាយ និងអង្គការ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការត្រួតពិនិត្យ និងការធ្វើសវនកម្មទាំងនោះ។

## ៣. ការធានាសេរីភាព និងការបង្កើតការផ្សាយសមធម៌ របស់ប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត

ដើម្បីលើកស្ទួយ និងកែលំអរប្រព័ន្ធផ្សព្វផ្សាយអោយស្របនឹងគោលការណ៍នៃសេរីភាពសារព័ត៌មាន សមធ៌ម ស្មើភាព និងការទទួលបានការផ្សព្វផ្សាយរបស់គណបក្សប្រកួតប្រជែង គណៈកម្មការគ្រប់គ្រងប្រពន្ធ័ផ្សព្វផ្សាយមួយត្រូវបានបង្កើតដើម្បីបង្កើតគោលការណ៍ ក្រមសីលធម៌ និងត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយជាពិសេសទូរទស្សន៍ វិទ្យុរដ្ឋ នៅក្នុងអំឡុងពេលបោះឆ្នោត។ គណៈកម្មការមានសិទ្ធិអំណាចលើក្រសួងព័ត៌មានទាក់ទិនការងារបោះឆ្នោត ក្នុងអំឡុងពេល បោះឆ្នោតដែលកំណត់ដោយច្បាប់បោះឆ្នោត។



សមាជិកនៃគណៈកម្មការគ្រប់គ្រងប្រពន្ធ័ផ្សព្វផ្សាយចំនួនប្រាំនាក់៖

* ពីរនាក់ត្រូវបានតែងតាំងដោយ គ.ជ.ប
* មួយនាក់ត្រូវបានតែងតាំងដោយក្រុមគណបក្សកាន់រដ្ឋាភិបាល
* មួយនាក់ត្រូវតែងតាំងដោយក្រុមគណបក្សក្រៅរដ្ឋាភិបាល ដែលមានអាសនៈក្នុងរដ្ឋសភា
* មួយនាក់ត្រូវតែងតាំងដោយក្រសួងព័ត៌មាន។

សមាជិកគណៈកម្មាធិការម្នាក់ក្នុងចំណោមពីរនាក់ដែលតែងតាំងដោយ គ.ជ.ប គឺ ជាប្រធានគណៈកម្មការនេះ។ គណកម្មការនេះជម្រុញ និងសហការ ការបង្កើតកម្មវិធីជជែកដេញដោល អំពីគោលនយោបាយ រវាងបេក្ខជនជានាយកមន្ត្រីនៃគណបក្សនយោបាយសំខាន់ៗឈរឈ្មោះបោះឆ្នោត។ក្នុងអំឡុងពេលបោះឆ្នោតគណៈកម្មការនេះត្រូវបង្កើតគោលការណ៍ព័ត៌មានសមធម៌ និងជម្រុញអោយប្រព័ន្ធផ្សព្វផ្សាយសោទស្សន៍គោរពគោលការណ៍នេះ។ គោលការណ៍សមធម៌ត្រូវធានាថាការផ្សព្វផ្សាយព័ត៌មានគណបក្សនយោបាយ និងគណបក្សនយោបាយដែលកើតឡើងដោយការរួមបញ្ចូលគ្នាពីគណបក្សនយោបាយផ្សេងៗឈរឈ្មោះបោះឆ្នោតគឺសមាមាត្រទៅនឹងចំនួនសន្លឹកឆ្នោតគាំទ្រ។ គណៈកម្មការនេះក៏ត្រូវគ្រប់គ្រងកម្មវិធីស្មើភាព និងការពិភាក្សាកម្មវិធីនយោបាយរបស់គណបក្សនយោបាយ និងបេក្ខជននៅក្នុងកុំឡុងពេលឃោសនាបោះឆ្នោត។ក្នុងអំឡុងពេលឃោសនាបោះឆ្នោត អ្នកគ្រប់គ្រងវិទ្យុ និងទូរទស្សន៍ឯកជនទាំងអស់ត្រូវជូនដំណឹងពីការលក់ម៉ោង ឬជួលម៉ោងផ្សាយទៅតាមតម្លៃទីផ្សារ មកគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមរយៈកិច្ចប្រជុំសម្របសម្រួលរបស់គណៈកម្មកាគ្រប់គ្រងប្រពន្ធ័ផ្សព្វផ្សាយ។ គណបក្សនយោបាយ ដែលឈរឈ្មោះបោះឆ្នោតអាចទាក់ទងទូរទស្សន៍ និងវិទ្យុឯកជនតាមការសម្របសម្រួលរបស់គណៈកម្មកាគ្រប់គ្រងប្រពន្ធ័ផ្សព្វផ្សាយ ដើម្បីទិញ និងជួលម៉ោងផ្សព្វផ្សាយកម្មវិធីនយោបាយ និងសារនយោបាយ។ គណៈកម្មការគ្រប់គ្រងប្រពន្ធ័ផ្សព្វផ្សាយត្រូវធ្វើគោលការណ៍ការលក់ ឬជួលម៉ោងរបស់វិទ្យុ និងទូរទស្សន៍ឯកជនផ្អែកទៅតាមគោលការណ៍ស្មើភាព តម្លៃស្មើៗគ្នា និងតាមលំដាប់មុនក្រោយ។

## ៤. យន្តការដោះស្រាយទំនាស់ និងវិវាទបោះឆ្នោត

យន្តការដោះស្រាយទំនាស់ និងវិវាទបោះឆ្នោតត្រូវបានកែទម្រង់ដើម្បីកំណត់នីតិវិធីច្បាស់លាស់ក្នុងការធានាយុត្តិធម៌សម្រាប់ការបោះឆ្នោត និងពង្រឹងឯករាជ្យភាពរបស់ស្ថាប័នក្នុងការអនុវត្តសមត្ថកិច្ចស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីបោះឆ្នោត។ ប្រព័ន្ធការដោះស្រាយវិវាទ និងបណ្ដឹងត្រូវបានចែកជាពីរ គឺការពិនិត្យជំនុំជម្រះសំរេច និងការផ្សះផ្សារដែលស្ថិតនៅក្រោមការទទួលខុសត្រូវ នៃរចនាសម្ព័ន្ធខុសគ្នារវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

⇒ **ប្រព័ន្ធ និងរចនាសម្ព័ន្ធថ្នាក់ជាតិ** *ដើម្បីពិនិត្យ និងជម្រះសម្រេចបណ្ដឹង បទល្មើសបោះឆ្នោត និងវិវាទបោះឆ្នោត ដែលក្រុមប្រឹក្សាធម្មនុញ្ញជាស្ថាប័នសំខាន់៖*

ក្រុមប្រឹក្សាធម្មនុញ្ញបង្កើតគណៈកម្មការយុត្តិធ៌មការបោះឆ្នោត (គ.យ.ប) ជាអង្គជំនុំជម្រះដំបូងរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីស៊ើបអង្កេត ពិនិត្យ ជម្រះ និងសម្រេចវិវាទ និងបណ្ដឹងបោះឆ្នោត។

ដើម្បីធានាតម្លាភាពនៃការជ្រើសរើស និងការទុកចិត្តទៅលើសមាសភាពស្ថាប័នថ្នាក់ជាតិ ការជ្រើសរើសសមាសភាពក្រុមប្រឹក្សាធម្មនុញ្ញគួរត្រូវបានកែលម្អ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមួយរូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ បួនរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយពីររូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងអតីតនាយករដ្ឋមន្ត្រីចាប់ពីឆ្នាំ១៩៩៣ជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញអចិន្ត្រៃយ៍។

ការជ្រើសតាំងបេក្ខជនសមាជិក ក្រុមប្រឹក្សាធម្មនុញ្ញដោយរដ្ឋសភា ធ្វើឡើងតាមរយៈគណៈកម្មការជ្រើសរើសមួយ។ គណៈកម្មការជ្រើសរើសនេះមានសមាសភាពចំនួនប្រាំរូប ដែលត្រូវតែងតាំងដោយប្រធានរដ្ឋសភាតាមរយៈសំណើរ

នៃគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភា។ នីតិវិធីនៃការជ្រើសរើសរបស់គណៈកម្មការនេះ មានបញ្ញត្តិនៅក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញជ្រើសតាំងដោយរដ្ឋសភា ត្រូវបានទទួលការយល់ព្រមពីរដ្ឋសភាចំនួនពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូលតាមសំណើរបស់គណៈកម្មការជ្រើសរើស ។

ការជ្រើសរើសបេក្ខជនសមាជិក គ.យ.ប ត្រូវបានចាត់ចែង ដោយគណៈកម្មការជ្រើសរើសមួយដែរ។ គណៈកម្មការជ្រើសរើសនេះមានសមាសភាពចំនួនប្រាំរូប ដែលត្រូវតែងតាំងដោយក្រុមប្រឹក្សា ធម្មនុញ្ញ។

ប្រធាន អនុប្រធាន និងសមាជិក គ.យ.ប ទាំងអស់ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ក្រោយពីបានទទួលការយល់ព្រមពីក្រុមប្រឹក្សាធម្មនុញ្ញចំនួនពីរភាគបី នៃសមាជិកក្រុមប្រឹក្សធម្មនុញ្ញទាំងមូល តាមសំណើរបស់គណៈកម្មការជ្រើសរើស។

លក្ខណៈសម្បត្តិសំខាន់ៗនៃសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និង គ.យ.ប ត្រូវមានពីឆន្ទៈ ការប្តេជ្ញាចិត្តពង្រឹងដំណើរការបោះឆ្នោតដោយសេរី យុត្តិធម៌ និងសុចរិតភាព គោរពក្រមសីលធម៌ ពិសេសអព្យាក្រឹត្យភាពមិនលម្អៀង ចៀសវាងរាល់ទំនាស់ផលប្រយោជន៍ និងអំពើពុករលួយ។

ក្រុមប្រឹក្សាធម្មនុញ្ញ ឬ គ.យ.ប មានសិទ្ធិអំណាចស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត ឬ/និងកោះហៅមន្ត្រីរៀបចំការបោះឆ្នោតគ្រប់ជាន់ថ្នាក់ ឬបុគ្គលពាក់ព័ន្ធមកសាកសួរ ឬ/និងបំភ្លឺចំពោះភាពមិនប្រក្រតីនៃចាត់ចែងការបោះឆ្នោត ចាប់ពីចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ឃោសនាបោះឆ្នោត បោះឆ្នោត និងរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលបោះឆ្នោត។

**⇒ប្រព័ន្ធរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ** *ដើម្បីសម្របសម្រួល និងផ្សះផ្សាវិវាទបោះឆ្នោត ដោយ គណៈកម្មការក្រោមជាតិរបស់គ.ជ.បៈ ដើម្បីអនុវត្តការសម្របសម្រួល និងផ្សះផ្សាវិវាទបោះឆ្នោតមានប្រសិទ្ធិភាព និងតម្លាភាពនៅថ្នាក់ក្រោមជាតិ គ.ជ.ប បង្កើតនាយកដ្ឋាននីតិកម្ម ដើម្បីគ្រប់គ្រង ការសម្របសម្រួល និងផ្សះផ្សាវិវាទបោះឆ្នោត ហើយធ្វើប្រតិភូកម្មអំណាចឲ្យគណៈកម្មការរាជធានី ខេត្តសម្រាប់យុត្តិធម៌ការបោះឆ្នោត និងគណៈកម្មការឃុំ សង្កាត់សម្រាប់យុត្តិធម៌ការបោះឆ្នោត។ ការជ្រើសរើសគណៈកម្មការទាំងនេះត្រូវអនុវត្តដូចនីតិវិធីនៃការជ្រើសរើស គធ/ខប និង គឃ/សប។*

## ៥. អព្យាក្រឹត្យភាពនៃសមាជិក និងភ្នាក់ងាររបស់ស្ថាប័នដែលមានសមត្ថកិច្ចដោយផ្ទាល់ក្នុងដំណើរការបោះឆ្នោត ដើម្បីបង្កើនបរិយាកាសបោះឆ្នោតដោយសេរី និងយុត្តិធម៌

សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិក គ.យ.ប សមាជិក គ.ជ.ប កងខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការមិនត្រូវជាមន្ត្រីនៃគណបក្សនយោបាយណាមួយបានឡើយក្នុងអំឡុងពេលបោះឆ្នោត។ មន្ត្រីគណបក្សនយោបាយ គឺជាសមាជិកសកម្មដែលមានការទទួលខុសត្រូវក្នុងរចនាសម្ព័ន្ធរបស់គណបក្សនៅគ្រប់លំដាប់ថ្នាក់ ហើយធ្វើសកម្មភាពគាំទ្រគណបក្សខ្លួន និង/ឬប្រឆាំងគណបក្សផ្សេងៗ។ មិនមានន័យថាបំបាត់សិទ្ធិនយោបាយរបស់

របស់ពួកគេទេ ជាក់ស្តែងអ្នករាយការណ៍ពិសេសសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានផ្តល់យោបល់ថា៖ មន្ត្រីរាជការ នគរបាល និងកងខេមរភូមិន្ទ មិនត្រូវចូលរួមក្នុងសកម្មភាពគណបក្សនយោបាយ។

**ជាសរុប** កំណែទម្រង់ការបោះឆ្នោតទៅលើចំនុចសំខាន់ៗខាងលើ អាចនាំមកបរិយាកាសនៃការទុកចិត្តថ្មីមួយពីគណបក្សសំខាន់ៗ មានអាសនៈក្នុងសភា។ គណបក្សសំខាន់ៗមានអាសនៈក្នុងសភា ដែលមានក្រុមគណបក្សកាន់រដ្ឋាភិបាល និងក្រុមគណបក្សក្រៅរដ្ឋាភិបាល គឺជាតួអង្គត្រួតពិនិត្យគ្នាទៅវិញទៅមក ក្នុងការសម្រេចចិត្ត និងមានការចូលរួមពីសាធារណៈជន។ ការកែទម្រង់គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ និងការបង្កើតគណៈកម្មការផ្សេងៗ ត្រូវអនុវត្តទៅតាមគោលការណ៍តម្លាភាព ក្នុងន័យពង្រឹងឯករាជ្យភាព និងបង្កើនសមត្ថកិច្ច សិទ្ធិអំណាច របស់ស្ថាប័ន និងគណៈកម្មការនានាទាំងនោះ។

ប្រព័ន្ធនៃការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតត្រូវបានផ្លាស់ប្តូរដោយឲ្យ គ.ជ.ប ជាស្ថា ប័នទទួលខុសត្រូវក្នុងការរៀបចំចាត់ចែង និងតាមបច្ចេកវិជ្ជាសាមញ្ញៗ ដើម្បីធានាសិទ្ធិបោះឆ្នោត និងគុណភាពបញ្ជីឈ្មោះបោះឆ្នោត។

កំណែទម្រង់ប្រព័ន្ធផ្សព្វផ្សាយពិសេសទូរទស្សន៍ និងវិទ្យុរដ្ឋត្រូវឲ្យមានគណៈកម្មការឯករាជ្យមួយសមាសភាពចំរុះ ដែលមានសិទ្ធិអំណាចជំនួសរដ្ឋាភិបាល ពិសេសក្រសួងព័ត៌មាន និងគ.ជ.ប ក្នុងការត្រួតពិនិត្យសម្រេច ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋក្នុងអំឡុងពេលបោះឆ្នោត។ គណៈកម្មការនេះមានសមត្ថកិច្ចក្នុងការបង្កើតគោលការណ៍កម្មវិធី និងការត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយ ដើម្បីធានាឲ្យមានការគោរពសេរីភាពព័ត៌មាន ការអនុវត្តន៍គោលការណ៍សមធម៌ និងតុល្យភាពព័ត៌មាននយោបាយក្នុងអំឡុងពេលបោះឆ្នោត។

**សន្ទានុក្រម៖**

* ក្រុមគណបក្សកាន់រដ្ឋាភិបាល៖ សំដៅទៅលើ គណបក្សមួយ ឬច្រើនចំរុះដែលដឹកនាំរដ្ឋាភិបាល (នីតិប្រតិបត្តិ)។
* ក្រុមគណបក្សក្រៅរដ្ឋាភិបាល៖ សំដៅទៅលើ គណបក្សមួយ ឬច្រើនមានអាសនៈនៅក្នុងរដ្ឋសភា ប៉ុន្តែមិនដឹកនាំ ឬចូលរួមដឹកនាំរដ្ឋាភិបាល។
* មន្ត្រីគណបក្សនយោបាយ៖ សំដៅទៅលើ សមាជិកសកម្ម របស់គណបក្សនយោបាយដែលមានការទទួលខុសត្រូវ ក្នុងរចនាសម្ព័ន្ធគណបក្ស នៅគ្រប់លំដាប់ថ្នាក់ ហើយធ្វើសកម្មភាពគាំទ្រគណបក្សខ្លួន ឬ/និង ប្រឆាំងគណបក្សផ្សេង។
* អំឡុងពេលបោះឆ្នោត៖ សំដៅទៅលើ អំឡុងពេលចាប់ផ្តើមពីការចុះឈ្មោះបេក្ខជនគណបក្ស យុទ្ធការបោះឆ្នោត ថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោតជាស្ថាពរ និយាយដោយឡែកអំឡុងពេលប្រតិទិន គ.ជ.ប រៀបចំការបោះឆ្នោត។
* មុនអំឡុងពេលបោះឆ្នោត៖ សំដៅទៅលើ អំឡុងពេលការចុះឈ្មោះអ្នកបោះឆ្នោត ការជ្រើសរើសសមាសភាព គ.ជ.ប ឬអំឡុង ចន្លោះពេលបោះឆ្នោត។
* សមធម៌សម្រាប់ការផ្សព្វផ្សាយបោះឆ្នោតដល់គណបក្សនយោបាយ ឬបេក្ខជន៖ សំដៅទៅលើ សមាមាត្រដែលគណបក្សនយោបាយ ឬបេក្ខជនទទួលបានការផ្សព្វផ្សាយ ដោយផ្អែកទៅលើចំនួនសន្លឹកឆ្នោតដែលគណបក្ស ឬបេក្ខជនទទួលបាននៅក្នុងអាណត្តិចុងក្រោយនៃរដ្ឋសភា។

# របាយការណ៍ប្រចាំឆ្នាំ ស្តីពី ប្រជាធិបតេយ្យ ការបោះឆ្នោត និងការកែទម្រង់




ខុមហ្វ្រែលបានបន្តសង្កេតមើលដូចឆ្នាំមុន ទៅលើការការធ្លាក់ចុះនៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មនេះ។ បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដោយអ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិផ្សេងៗគ្នា ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាក៏ដោយ នៅឆ្នាំ2013 ត្រូវបានគេកត់សម្គាល់ឃើញថា លទ្ធិប្រជាធិបតេយ្យហាក់នៅស្ងៀម ហើយបានបន្តពីរទសវត្សរ៍នៃភាពមិនច្បាស់លាស់ចំពោះទិសដៅនយោបាយនាពេលអនាគតរបស់ប្រទេសកម្ពុជា។ ក្នុងឆ្នាំ 2013 សាធារណជនកម្ពុជាកាន់តែច្រើនឡើងបានសម្តែងនូវការលំបាករបស់ពួកគេនៅលើភាពមិនប្រាកដប្រជាផ្នែកនយោបាយដែលនាំទៅរកការកើនឡើងមួយនៅក្នុងការធ្វើកូដកម្មការតវ៉ា បាតុកម្ម និងការសម្តែងផ្សេងទៀតនៃការមិនសប្បាយចិត្តជាពិសេសកំណើនការបោះឆ្នោតសម្រាប់គណបក្សប្រឆាំងនៅក្នុងការបោះឆ្នោតសភានៅក្នុងខែកក្កដានេះ។ នៅចុងឆ្នាំ 2013 ការប៉ះទង្គិចគ្នាដ៏អាក្រក់មួយបានកើតឡើងរវាងកងកម្លាំងសន្តិសុខ ការប្រឆាំង និងកម្មករដែលធ្វើកូដកម្ម បានសម្គាល់ថា វិបត្តិនយោបាយ និងសង្គមកាន់តែមានភាពជ្រាលជ្រៅ និងបន្តមកដល់ឆ្នាំ 2014 ។

របាយការណ៍វិភាគដែលមានចំណងជើងថា" **ប្រជាធិបតេយ្យ ការបោះឆ្នោត និងកំណែទម្រង់** "ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ និងផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធដែលចាប់អារម្មណ៍ទាំងអស់។

ការផលិតរបាយការណ៍នេះ គឺមានគោលបំណងដើម្បីបង្កើតទិន្នន័យជាក់ស្តែងនៅលើដំណើរការប្រជាធិបតេយ្យភាវូបនីយកម្ម និងដើម្បីផ្តល់ការវិភាគដ៏ទូលំទូលាយនិងការតស៊ូមតិសម្រាប់អ្នកពាក់ព័ន្ធជាតិ និងអន្តរជាតិដែលចងក្រងដំណើរការប្រជាធិបតេយ្យកម្ពុជា។ របាយការណ៍នេះក៏បានបង្ហាញសំណួរដែលនាំឲ្យមានការវិភាគនិងការវាយតម្លៃប្រចាំឆ្នាំ នៃដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មនៅប្រទេសកម្ពុជាដូចជា៖ តើប្រព័ន្ធនយោបាយរបស់ប្រទេសកម្ពុជាកំពុងតែមានដំណើរការឆ្ពោះទៅរកការបង្កើតលទ្ធិប្រជាធិបតេយ្យមួយ ឬត្រូវដើរថយក្រោយ ឬដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មបានបញ្ចប់?

**លោកអ្នកអាចតាមដាន និងចម្លងយកឯកសារនេះ សូមចុចលើតំណភ្ជាប់នេះ://** http://www.comfrel.org/eng/index.php?option=com_content&view=article&id=749:2013-annual-report-democratic-election-and-reform-in-cambodia&catid=188:other **ឬរបាយការណ៍នានា និងឯកសារផ្សេងៗដែលពាក់ព័ន្ធដោយចូលទៅកាន់វេបសាយរបស់ខុមហ្វ្រែល** www.comfrel.org





# កិច្ចពិភាក្សាតុមូល ស្តីពីការបោះឆ្នោត ជាមួយយុវជន

កំណែទម្រង់ការបោះឆ្នោតត្រូវបានគេកំពុងយកចិត្តទុកដាក់ និងចងក្រងបណ្តាញដើម្បីប្រមូលផ្តុំទាំងមតិយោបល់ និងពីអ្នកបច្ចេកទេសក្នុងការតស៊ូមតិឲ្យមានការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា ដើម្បីឲ្យកាន់តែមានភាពល្អប្រសើរ និងជៀសវាងជម្លោះនយោបាយក្រោយការបោះឆ្នោត។

ក្នុងពេលទន្ទឹមគ្នានេះយុវជនត្រូវបានគេទទួលស្គាល់ថាជាធនធានដ៏សំខាន់ និងត្រូវបានគេយកចិត្តទុកដាក់ក្នុងការចូលរួមកំណែទម្រង់នេះ តាមដែលអាចធ្វើទៅបាន។

ខុមហ្វ្រែលបានកំពុងកម្មវិធីកិច្ចពិភាក្សាតមូលនេះ ក្នុងគោលបំណងលើកទឹកចិត្ត យុវជនឲ្យចូលរួមក្នុងកំណែទម្រង់ការបោះឆ្នោត និងបន្ថែមការយល់ដឹងដល់ពួកគាត់ឲ្យយល់ដឹងពីតួនាទីដ៏មានសារៈសំខាន់ នៅក្នុងការចូលរួមបោះឆ្នោតព្រមទាំងមូលមតិយោបល់ ក៏ដូចជាអនុសាសន៍នានាពីយុវជន ដើម្បីធ្វើឱ្យប្រសើរឡើង សម្រាប់ការរៀបចំការបោះឆ្នោត អណត្តិក្រោយទៀត។

ជាក់ស្តែងនៅវេលាម៉ោង៨.០០នាទីព្រឹក ថ្ងៃទី១៨ មិថុនា ឆ្នាំ២០១៤ លេខាខុមហ្វ្រែលខេត្តកំពង់ធំ បានរៀបចំកិច្ចប្រជុំតុមូលយុវជន ពី **ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ***នៅសាលាឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយខេត្តកំពង់ធំ***។ ក្នុងកម្មវិធីនេះ មានការអញ្ជើញចូលរួមពីយុវជន អាជ្ញាធរមូលដ្ឋាន សហគមន៍ សកម្មជន គណបក្សនយោបាយ សរុបចំនួន១០នាក់ ស្រី៥នាក់។





កិច្ចប្រជុំតុមូលយុវជន ពី **ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ***នៅសាលាឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ*** (ថ្ងៃទី១៨ មិថុនា ឆ្នាំ២០១៤ )



កិច្ចប្រជុំតុមូលយុវជន ពី កំណែទម្រង់ការបោះឆ្នោត ក្រោមប្រធានបទ "ការចុះឈ្មោះ និងបញ្ជីឈ្មោះបោះឆ្នោត" នៅ***ខេត្តកំពង់ ឆ្នាំង***

(ខែ ឧសភា ឆ្នាំ២០១៤ )



# កិច្ចពិភាក្សាតុមូលស្តីពី ការកែទម្រង់ការបោះឆ្នោត




ក្រោមជំនួយពីUSAID តាមរយៈមូលនិធិអន្តរជាតិសម្រាប់ប្រព័ន្ធបោះឆ្នោត (IFES) និងការសហការណ៍ជាមួយសម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត (ERA) ខុមហ្វ្រែលបានផលិតកម្មវិធីកិច្ចពិភាក្សាតុមូលស្តីពីការកែទម្រង់ការបោះឆ្នោត ដែលបានលើកយកនូវប្រធានបទសំខាន់ៗចំនួន៩ ទាក់ទងនឹងការកែទម្រង់ការបោះឆ្នោតនៅកម្ពុជា។

ប្រធានបទទាំង៩ នោះរួមមាន៖ ការកែទម្រង់គ.ជ.ប ការកែទម្រង់ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយ យន្តការដោះស្រាយបណ្តឹង និងជម្លោះបោះឆ្នោត ហិរញ្ញវត្ថុគណបក្សនយោបាយសម្រាប់ការឃោសនាបោះឆ្នោត អព្យាក្រឹត្យភាពកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការ គោលនយោបាយកំណត់កូតាស្ត្រី ការលើកកម្ពស់ និងធានាសិទ្ធិបោះឆ្នោតរបស់ជនជាតិដើមភាគតិច និងជនពិការ និងស្តង់ដានៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌។




កញ្ញា ខួត តារា (ពិការដៃ) កំពុងបញ្ចេញយោបល់ និសួរសំណួរទៅវាគ្មិន (១១ មិថុនា ឆ្នាំ២០១៤)






គោលបំណងនៃការផលិតកម្មវិធីកម្មវិធីពិភាក្សាតុមូលនេះឡើង គឺដើម្បីផ្សព្វផ្សាយពីប្រធានបទសំខាន់ៗ នៃការបោះឆ្នោត ដែលត្រូវតែធ្វើការកែទម្រង់ និងផ្សព្វផ្សាយទៅដល់ម្ចាស់ឆ្នោត និងភាគីដែលពាក់ព័ន្ធឲ្យបានដឹង។ ការរៀបចំកិច្ចពិភាក្សានេះផងដែរ ក៏មានការចូលរួមពីសិស្ស និសិត្ស យុវជនអង្គការ សមាគមព្រះសង្ឃ ដើម្បីជជែកពិភាក្សា សួរសំណួរ ហើយកម្មវិធីនេះក៏ត្រូវយកចាក់ផ្សាយតាមរយៈវិទ្យុ ដាក់លើគេហទំព័រជាសម្លេង និងវីដេអូ និងចែករំលែកទៅសាធារណៈជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងផលិតជាវីដេអូស៊ីឌី ហើយក៏បន្តផ្សព្វផ្សាយទៅបណ្តាញខុមហ្វ្រែលតាមខេត្ត និងវិទ្យុក្នុងខេត្តមួយចំនួនផងដែរ។

លោកអ្នក ក៏អាចស្វែងរកឯកសារជាវីដេអូ និងសម្លេងដោយចូលទៅកាន់គេហទំព័រ www.comfrel.org រួចស្វែងរកសម្លេងសង្គមស៊ីវិល

# សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត

## The Electoral Reform Alliance (ERA)

សម្ព័ន្ធកំណែទម្រង់ការបោះឆ្នោត បានរៀបចំសិក្ខាសាលាបង្ហាញអំពី "**សេចក្តីស្នើវិសោធនកម្មក្របខណ្ឌច្បាប់ទាក់ទងស្ថាប័នគ្រប់គ្រងការបោះឆ្នោត យន្តការដោះស្រាយវិវាទបោះឆ្នោត ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត និងប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលបោះឆ្នោត**" កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៤ នៅសណ្ឋាគារហ៊ីម៉ាវ៉ារិ, រាជធានីភ្នំពេញ។

សិក្ខាសាលាបង្ហាញនេះ មានការថ្លែងសន្ទរកថា និងមតិបើកសិក្ខាសាលាដោយ លោក **សុរិយា ប្រាសាទ ស៊ូប៊ែឌី** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក **ធន សារ៉ាយ** ប្រធានសមាគមអាដហុក និងការថ្លែងសុន្ទរកថាបិទកម្មវិធីដោយលោកស្រី **ធីតា ឃឹះ** នាយិការអង្គការសីលការ និងជាប្រធានគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុង វិស័យនយោបាយ ចូលរួមផងដែរ។





**គោលបំណងនៃសិក្ខាសាលានេះគឺ** ដើម្បីបង្ហាញជូនភាគីពាក់ព័ន្ធអំពីសេចក្តីស្នើវិសោធនកម្មក្របខ័ណ្ឌច្បាប់ទាំងនោះព្រមទាំងពិភាក្សាជាមួយភាគីពាក់ពាក់ព័ន្ធអំពីសេចក្តីស្នើវិសោធនកម្មក្របខ័ណ្ឌច្បាប់ទាំងនោះផងដែរ។



# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការចេញផ្សាយសៀវភៅរដ្ឋសភា ជីវប្រវត្តិសង្ខេបតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៥ និងដំណើរវេទិកាសួរអ្នកតំណាង

គណៈកម្មធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា បាននិង កំពុងដំណើរការកម្មវិធីឃ្លាំមើលសភា និង តំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ និងកម្មវិធីវេទិការសួរអ្នកតំណាង។ ខុមហ្វ្រែល បានផលិត និងចងក្រងឯកសារ និងទិន្នន័យ ដើម្បីផលិតសៀវភៅស្តីពីរដ្ឋសភា ជីវប្រវត្តិសង្ខេបតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ នីតិកាលទី៥នៃរដ្ឋសភា។

កម្មវិធីឃ្លាំមើលរដ្ឋសភា នឹងផ្តល់របាយការណ៍ឆមាស និងរបាយការណ៍ប្រចាំឆ្នាំ អំពីដំណើរការរបស់រដ្ឋសភា និងសកម្មភាពរបស់តំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោត។ សៀវភៅសភា និងជីវប្រវត្តិសង្ខេបតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ ផលិតលើកទីមួយ ក្នុងខែមិថុនា ឆ្នាំ២០១៤។ សៀវភៅនេះមិនត្រឹមតែមានព័ត៌មានស្តីពីតំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រនោះទេ ថែមទាំងមានព័ត៌សំខាន់ៗមួយចំនួនដូចជា៖ អង្គការលេខនៃរដ្ឋសភា ដំណើរការនៃការបង្កើត ច្បាប់សិទ្ធិ និងអំណាចរបស់រដ្ឋសភាជាដើម។ សៀវភៅនេះត្រូវបានផលិតជាលើកទី១ នាពេលនេះ នៅមានការខ្វះខាតដូចជាព័ត៌មានជីវប្រវត្តិតំណាងរាស្ត្រមួយចំនួន។ ដំណើរការផលិតសៀវភៅនេះ ជួបការលំបាកមួយចំនួនដូចជា៖ ការខ្វះខាត ការសហការរបស់តំណាងរាស្ត្រ ឬបេក្ខជនជាប់ឆ្នោត អគ្គលេខាធិការដ្ឋាន, គណបក្សនយោបាយជាប់ឆ្នោត និងស្ថាប័នដែលពាក់ព័ន្ធ។

ជីវប្រវត្តិសង្ខេបតំណាងរាស្ត្រ និង បេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រចំនួន១២៣រូប ត្រូវបានចងក្រងក្នុងសៀវភៅនេះ។ ខុមហ្វ្រែលបានប្រមូលព័ត៌មានអ្នកទាំង១២៣រូប រួចបញ្ជូលព័ត៌មានរបស់តំណាងរាស្ត្រ ឬបេក្ខជនជាប់ឆ្នោតនីមួយ ដើម្បីឲ្យ ពួកគេធ្វើការកែតម្រូវ និងបំពេញបន្ថែមនូវរាល់ព័ត៌មានដែលខ្វះខាត។ ជាលទ្ធផល មានតែបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រចំនួន២៧រូបមកពីគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ បានសហការផ្តល់ព័ត៌មានទាំងនោះមកខុមហ្វ្រែល។ ខុមហ្វ្រែលមានការលំបាកក្នុងប្រមូលព័ត៌មាននៃតំណាងរាស្ត្រ ឬបេក្ខជនជាប់ឆ្នោតអំពីអាសយដ្ឋាន លេខទូរស័ព្ទទំនាក់ទំនង កម្រិតវប្បធម៌ ជំនាញឯកទេសផ្សេងៗ វិស័យដែលតំណាងរាស្ត្រមានចំណាប់អារម្មណ៍ និងបទពិសោធការងាររបស់ពួកគេ ដោយសារមិនទទួលបានកិច្ចសហការពីរដ្ឋសភា គណៈកម្មាធិការរៀបចំការបោះឆ្នោត គ.ជ.ប ព្រមទាំងគណបក្សប្រជាជនកម្ពុជា និងបេក្ខជនជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិមួយចំនួនផងដែរ។

ខុមហ្វ្រែលបានផ្ញើលិខិតទៅកាន់តំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា តាមរយៈរដ្ឋសភា ដើម្បីស្នើសុំព័ត៌មានទាំងនោះពីតំណាងរាស្ត្រទាំង៦៨រូប ប៉ុន្តែរដ្ឋសភាបានបដិសេធមិនបញ្ជូនលិខិតទាំងទៅកាន់តំណាងរាស្ត្រនោះទេ។ បន្ទាប់ពីទទួលបានការបដិសេធពីរដ្ឋសភា ខុមហ្វ្រែល

បានដាក់ទៅតំណាងរាស្ត្រជាថ្មីម្តងទៀត តាមរយៈទីស្នាក់កាលកណ្តាល គណបក្សប្រជាជនកម្ពុជានៅភ្នំពេញ ក្នុងគោលបំណងដូចខាងលើ ប៉ុន្តែគណបក្សប្រជាជនកម្ពុជាបានបដិសេធមិនបញ្ជូន លិខិតទៅតំណាងរាស្ត្ររបស់ខ្លួន។ ក្រោយពីបានទទួលបានការបដិសេធចំនួនពីរលើកដូចបានរៀបរាប់ខាងលើ យើងបាន ស្នើសុំអាសយដ្ឋានរបស់តំណាងគណបក្សប្រជាជនកម្ពុជាទាំង៦៨រូប ដើម្បីដាក់លិខិតទៅអ្នកតំណាងរាស្ត្រដោយផ្ទាល់ ប៉ុន្តែសំណើរនៅតែត្រូវបានបដិសេធពីគណបក្សប្រជាជនដដែល។មកដល់ពេលនេះ លិខិតដែលផ្ញើរទៅកាន់តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាទាំង៦៨រូប ត្រូវបានដាក់នៅការិយាតំណាងរាស្ត្រនៃរាជធានី/ខេត្តនីមួយៗ។




សម្រាប់បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិវិញ ខុមហ្វ្រែលបានដាក់លិខិតទៅពួកគេទាំង៥៥រូប តាមរយៈស្នាក់ការកណ្តាលគណបក្សសង្គ្រោះជាតិនៅរាជធានីភ្នំពេញ ដើម្បីស្នើសុំព័ត៌មានខាងលើផងដែរ។ លិខិតទាំង៥៥នោះ បានផ្ញើរទៅបេក្ខជនជាប់ឆ្នោតទាំងនោះ ប៉ុន្តែមានតែបេក្ខជនជាប់ឆ្នោត២៧រូបតែប៉ុណ្ណោះដែលបានឆ្លើយតប និងផ្តល់ព័ត៌មានតាមការស្នើសុំ។ បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ហាក់ដូចជាមានការប្រុងប្រយ័ត្នខ្ពស់ក្នុងសហការផលិតសៀវភៅដែលបោះពុម្ពលើកទី០១ នាពេលនេះ ព្រោះខ្លាចក្រែងត្រូវបានគេយល់ ច្រឡំថាខ្លួនទទួលស្គាល់ពីភាពស្របច្បាប់នៃរដ្ឋសភានាពេលបច្ចុប្បន្ន។

សាធារណៈជនអាចទាញយកសៀវភៅនេះពីគេហទំព័ររបស់ខុមហ្វ្រែលខាងក្រោមនេះ៖ http://www.comfrel.org/components/com_mypublications/files/644652Final_MPs_directory_Printout_2013_2018_MP_Directory__Khmer____1st_Edition.pdf

ស្របពេលជាមួយគ្នានេះ ខុមហ្វ្រែល បាននិងកំពុងផលិតគម្រោងថ្មីមួយទៀតដែលមានឈ្មោះថា **វេទិកាសួរអ្នកតំណាង** ជាភាសាអង់គ្លេស "Ask Your MP" ដែលពុំធ្លាប់មាននៅក្នុងប្រទេសកម្ពុជានាពេលកន្លងមក។ គម្រោងនេះឲ្យប្រជាពលរដ្ឋ និងតំណាងរាស្ត្រមានឱកាស ផ្លាស់ប្តូរព័ត៌មាន និងមតិយោបល់គ្នា។ ប្រជាពលរដ្ឋអាចលើកសំណួរ ឬមតិយោបល់ទៅកាន់អ្នកតំណាង ដោយប្រើប្រាស់មធ្យោបាយដែលបានផ្តល់ជូនដោយគម្រោងនេះដូចជា៖ ការផ្ញើសារជាអក្សរតាមរយៈទូរស័ព្ទ សារអេឡិចត្រូនិច (អ៊ីម៉ែល) គេហទំព័រ Facebook ឬគេហទំព័រសម្លេងម្ចាស់ឆ្នោត និងការផ្ញើសារជាសម្លេងតាមរយៈទូរស័ព្ទ (Freedom Fone)។

បញ្ហាប្រឈមនៃដំណើរការវេទិកានេះ គឺការចូលរួមរបស់តំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ។ មកដល់ពេលនេះមានតែបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចំនួន២៧រូប និងសមាជិកសភាគណបក្ស ប្រជាជនកម្ពុជា ១រូបតែប៉ុណ្ណោះ ដែលបានចូលរួមក្នុងវេទិកានេះ។

ប្រជាពលរដ្ឋ ជាពិសេសម្ចាស់ឆ្នោតអាចសួរសំនួរទៅអ្នកតំណាង (តំណាងរាស្ត្រ និងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ)តាម រយៈមធ្យោបាយដូចបានផ្តល់ជូនខាងក្រោម៖

**ទូរស័ព្ទលេខ** ៖ ០១០/០១៥ ៨០២ ៧៧៧ ឬ ០១២ ៤១០ ១០០ ឬ ០៨៨ ៣៣៣ ២១០០

**ផ្ញើសារជាអក្សរ** ៖ ០១០ ៥៣ ៥៣ ៥៤ ឬ ០១៧ ៦១០ ៣៥១

**អ៊ីម៉ែល** ៖ SOURSAKPHEA@online.com.kh

**ហ្វេសប៊ុក** ៖ www.facebook.com/comfrel.org/app_156218351098324

**គេហទំព័រCVV** ៖ http://www.cambodianvotervoice.org/kh/SOURSAKPHEA.html

ការឆ្លើយតបរបស់អ្នកតំណាង និងខ្លឹមសារលំអិតនៃវេទិកានេះ នឹងធ្វើការចាក់ផ្សាយតាមរយៈកម្មវិធីសម្លេងម្ចាស់ឆ្នោត នៃ ការផ្សាយសម្លេងសង្គមស៊ីវិលតាមរយៈស្ថានីយ៍វិទ្យុ FM 105 Mz រៀងរាល់ថ្ងៃច័ន្ទសប្តាហ៍ទី០២ នៃខែនីមួយៗ វេលា ម៉ោង ០៧ និង៣០នាទី រហូតដល់ ម៉ោង ០៨ និង៣០នាទីព្រឹកផងដែរ។

ជាសរុប ខុមហ្វ្រែល សង្ឃឹមថាគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ និងសម្រេច ដំណោះស្រាយនយោបាយ ហើយរដ្ឋសភានឹងមានតែតមនាងរាស្ត្រ ឬសមាជិកសភា ទាំងពីរគណបក្ស នៅពេលនោះខុមហ្វ្រែល នឹងទទួលការសហការ ពេញលេញពីរដ្ឋសភា, តំណាងរាស្ត្រ, សមាជិកសភា, អគ្គលេខាធិការដ្ឋានរដ្ឋសភា និងគណបក្សទាំងពីរ ដើម្បីផលិតសៀវភៅរដ្ឋសភា និងជីវប្រវត្តសង្ខេប តំណាងរាស្ត្រ/សមាជិកសភា ជាការបោះពុម្ពផ្សាយជាលើកទី២ ដែលមានព័ត៌មានពេញលេញ។ ខុមហ្វ្រែល ក៏សង្ឃឹមថាកម្មវិធីវេទិកាសួរអ្នកតំណាង "Ask Your MP" នឹងដំណើការដោយមានការចូលរួម និងគាំទ្រពីតំណាងរាស្ត្រ ឬសមាជិកនៃរដ្ឋសភាបន្ថែមទៀត។



# សេចក្តីប្រកាសព័ត៌មាន
# អត្ថបទស្តីពី
# ការរំលោភច្បាប់ និងការជ្រៀតជ្រែកនយោបាយក្នុងដំណើរការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និង ក្រុង/ស្រុក/ខណ្ឌ អាណត្តិទី២

ចាប់ពីថ្ងៃទី០២ ដល់ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ គឺជាអំឡុងពេលនៃ ការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ ស្រុក/ខណ្ឌ នីតិកាលទីពីរ។ គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោតមានសកម្មភាពឃោសនារៀងខ្លួនៗ។ ក្នុងចំណោមគណបក្សនយោបាយទាំង០៥ គណបក្សសង្គ្រោះជាតិបានរៀបចំការឃោសនាយ៉ាងសកម្មជាងគណបក្សនយោបាយដទៃ ដោយគណបក្សនេះរៀបចំការប្រមូលផ្តុំ ប្រជាពលរដ្ឋដែលគាំទ្រគណបក្ស និងរហូតដល់មានការហែក្បួនតាមផ្លូវសាធារណៈទៀតផង។

ការប្រមូលផ្តុំ និងការហែក្បួនឃោសនាបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិនាពេលនេះគឺស្របពេលដែល អាជ្ញាធរក៏ដូចជារាជរដ្ឋាភិបាលរបស់គណបក្សប្រជាជនកម្ពុជា បានកំពុងរឹតបណ្តឹងសេរីភាពនៃការជួបជុំបញ្ចេញមតិតាមរយៈការប្រមូលផ្តុំ និងបាតុកម្មដោយសន្តិវិធី។ នៅថ្ងៃទី ៣០ ខែមេសា ២០១៤ សាលារាជធានីភ្នំពេញមិនត្រឹមតែបានស្នើឲ្យគណៈកម្មាធិការរៀបចំការបោះឆ្នោត រាជធានីភ្នំពេញមិនអនុញ្ញាតឲ្យគណបក្សនយោបាយធ្វើការប្រមូលផ្តុំ និងដង្ហែក្បួនឃោសនាតាមទីតាំង និងដងផ្លូវសាធារណៈ ថែមទាំងព្រមានចាត់វិធានការបញ្ឈប់រាល់ការឃោសនាទាំងឡាយណារបស់គណបក្សនយោបាយ បេក្ខជន ឬតំណាងដែលប្រាសចាកពីច្បាប់ បទបញ្ជា និងលិខិតបទដ្ឋានគតិយុត្តនានា។ លិខិតអន្តរាគមន៍របស់សាលារាជធានី គឺគ្មានមូលដ្ឋានគតិយុត្តិ និងខុសសមត្ថកិច្ចទាំងស្រុង។ខណៈការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះ ស្ថិតនៅក្រោមការសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត "គ.ជ.ប" ដែលបានចែងក្នុងមាត្រា០៩ និងមាត្រា១០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ។

ពាក់ព័ន្ធនឹងបំរាមដែលមិនអនុញ្ញាតឲ្យមានការជួបជុំ ឬប្រមូលផ្តុំគ្នាដែលចេញដោយក្រសួងមហាផ្ទៃ និងសាលារាជធានីភ្នំពេញ គណបក្សជាតិនិយមធ្លាប់ស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការពិនិត្យលើធម្មនុញ្ញភាព និងបកស្រាយបំរាមខាងលើ ប៉ុន្តែសំណើរនេះត្រូវបានបដិសេធដោយក្រុមប្រឹក្សាធម្មនុញ្ញបានអះអាងថាខុស សមត្ថកិច្ចរបស់ខ្លួន។ ការបដិសេធរបស់ក្រុមប្រឹក្សាធម្មនុញ្ញនេះគឺបង្ហាញឲ្យឃើញពីកង្វះនៃការទទួលខុសត្រូវរបស់ ស្ថាប័ននេះដែលនាំឲ្យការអនុវត្តសិទ្ធិសេរីភាពមិនត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។

ខុមហ្វ្រែលបានថ្កោលទោសសំណើររបស់សាលារាជធានីភ្នំពេញដែលរំលោភរដ្ឋធម្មនុញ្ញ និងច្បាប់ និងជ្រៀតជ្រែកលើសមត្ថកិច្ចរបស់ គ.ជ.ប ដែលច្បាប់ស្តីពីបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ មាត្រា៤៥ តម្រូវឲ្យ គ.ជ.ប ចាត់ចែងដំណើរឃោសនាបោះឆ្នោតត្រូវគោរពតាមវិធានបទបញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងច្បាប់ស្តីពីការឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ក្រមសីលធម៌ បទបញ្ជា និងនីតិវិធីគោរពតាមគោលតេការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបយ្យដូចមានចែកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

លិខិត្តរបស់សាលារាជធានីភ្នំពេញដែលបានចេញនៅថ្ងៃខាងលើនេះបានរំលោភក្របខ័ណ្ឌច្បាប់ដែលមានជាធរមានយ៉ាងធ្ងន់ធ្ងរ ឬជាលិខិត្តអនាគតិដោយដាក់ចេញនូវវិធានការណ៍មួយ។ ក្នុងអំឡុងពេលឃោសនាបោះឆ្នោតនេះ ក្រសួងមហាផ្ទៃ និងអាជ្ញាធរសាលារាជធានីភ្នំពេញបន្តការហាមប្រមូលផ្តុំនៅទីលានប្រជាធិបតេយ្យដោយគ្មានយោងតាមច្បាប់ និងមូលហេតុច្បាស់លាស់ ហើយថែមទាំងប្រើប្រាស់កម្លាំងសន្តិសុខមិនផ្លូវការប្រើ អំពើហឹង្សាទៅលើមន្ត្រីជាប់ឆ្នោត ឬប្រជាពលរដ្ឋដែលព្យាយាមប្រមូលផ្តុំគ្នា និងអ្នកសារព័ត៌មានកំពុងបំពេញភារកិច្ចនៅទីនោះ។ ក្រសួងមហាផ្ទៃធ្លាប់បានពន្យល់ថា កម្ពុជា ឬរាជធានីភ្នំពេញកំពុងស្ថិតនៅភាពអាសន្ន។

រាជរដ្ឋាភិបាល និងអាជ្ញាធរនៃគណបក្សប្រជាជនកម្ពុជាមិនត្រឹមតែរំលោភច្បាប់បោះឆ្នោត ថែមទាំងរំលោភមាត្រា៣៧ និងមាត្រា៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា រួមទាំងមាត្រា០៤ និងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តី ពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាក៏ជាប្រទេសហត្ថលេខីផងដែរ។ *មាត្រា០៤ នៃកតិកាសញ្ញានោះ "ក្នុងករណី មានភាពអាសន្នសាធារណៈពិសេសដែលគំរាមកំហែងដល់អត្ថិភាពជាតិ និងដែលត្រូវបានប្រកាស ជាផ្លូវការ រដ្ឋជាភាគីនៃកតិកាសញ្ញានេះអាចចាត់វិធានការបដិប្បញ្ញត្តិនឹងកាតួកិច្ច ដែលមានចែងក្នុងកតិកាសញ្ញានេះ ក្នុងកម្រិតដែលស្ថានភាពតម្រូវតែប៉ុណ្ណោះ............"។ មកដល់ពេលបច្ចុប្បន្នមាត្រា២២ នៃរដ្ឋធម្មនុញ្ញមិនត្រូវបានអនុវត្តនៅឡើយព្រះមហាក្សត្រមិនទាន់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានសភា និងប្រធានព្រឹទ្ធសភា។* បន្ទាប់មក អាជ្ញាធរសាលារាជធានីក៏យកលេសបន្ថែមពីការដាក់ទីលានប្រជាធិបតេយ្យក្នុងការស៊ើបអង្កេតករណីអំពើហឹង្សាក្នុងការតវ៉ា របស់កម្មករ ដែលហេតុការណ៍នោះបានកើតឡើងនៅទីកន្លែងផ្សេងៗដូចជា ទីតាំងផ្លូវវែងស្រែង និង តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញផ្លូវជាតិលេខ៤។ តុលាការក៏បានបញ្ចប់នីតិវិធីស៊ើបអង្កេតលើសំណុំរឿងនោះដោយបានបើកសវនាការជំនុំជម្រះជាបន្តបន្ទាប់ផងដែរ។

មាត្រា៤៦នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌបានចង្អុល បង្ហាញច្បាស់ថា ការឃោសនាត្រូវអនុវត្តទៅតាម បទបញ្ញត្តិជំពូកទី៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ សម្រាប់សកម្មភាពឃោសនាបោះឆ្នោត តម្រូវឲ្យអ្នកគ្រប់គ្រងឧទ្យានសាធារណៈ និងសាលសាធារណៈត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ។ សាលារាជធានីភ្នំពេញមិនអនុវត្តដូចបទបញ្ញត្តិខាងលើនោះទេ ថែមទាំងបដិសេធការស្នើសុំទីលានប្រជាធិតេយ្យ ឬសួនការ៉ូឡាខាងកើតចំហៀងខាងត្បូងវត្តបុទុមវត្តី រាជធានីភ្នំពេញសម្រាប់ការឃោសនាបោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិចំនួនពីរលើក។

មិនតែប៉ុណ្ណោះនៅថ្ងៃទី០២ ឧសភា ឆ្នាំ២០១៤ អាជ្ញាធរសាលារាជធានីភ្នំពេញនៃគណបក្សប្រជាជនកម្ពុជា បានស្នើឲ្យគណៈកម្មការរៀបចំការបោះឆ្នោត រាជធានីភ្នំពេញចាត់វិធានការចំពោះគណបក្សសង្គ្រោះជាតិ ដែលបានធ្វើសកម្មភាពឃោសនាដោយមានការប្រមូលផ្តុំ និងប្រើប្រាស់សកម្មជនរបស់ខ្លួន ព្រមទាំងចាត់តាំងឲ្យមានការដង្ហែក្បួនតាមដងផ្លូវសាធារណៈ។ ផ្នែកទី៦ ប្រការ២.៧៦ នៃ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ ខេត្ត និងក្រុង/ស្រុក/ខណ្ឌ អាណត្តិទី២ ដែលប្រកាសឲ្យប្រើដោយ គ.ជ.ប កាលពីថ្ងៃទី១៦ មករា ២០១៤ បានកំណត់ពីសកម្មភាពឃោសនា ជាសកម្មភាពដែលធ្វើឡើងជាសាធារណៈដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ។ សកម្មភាពទាំងនោះមានដូចជា៖ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន និងជាសកម្មភាពការជួបជុំ ឬការរៀបចំជាក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ឬការឃោសនាតាមផ្ទះ ជាដើម។

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ នៅថ្ងៃទី៣០ មេសា ២០១៤ បានស្នើឲ្យ គ.ជ.ប ចាត់វិធានការចំពោះការរំលោភបំពានច្បាប់ បទបញ្ជា និងនីតិវិធីបោះឆ្នោតដោយអាជ្ញាធរ។ ក្រោយពីមានប្រតិ កម្ម គ.ជ.ប នៅថ្ងៃទី០៦ ខែឧសភា ២០១៤ បានធ្វើលិខិតស្នើទៅគ្រប់អភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី/ខេត្ត ដើម្បីបង្កលក្ខណៈសមស្របដល់គណបក្សនយោបាយ និងបេក្ខជនជនធ្វើ សកម្មភាពឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក /ខណ្ឌ ក្នុងការជួបជុំគ្នានៅតាមទីសាធារណៈ និងដង្ហែក្បួននៅតាមទីសាធារណៈក្នុងរូបភាពទ្រង់ទ្រាយសមស្របធានា បាននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់រៀបរយល្អ។ ទោះបីជា គ.ជ.ប បានធ្វើការណែនាំទៅដល់អាជ្ញាធររាជធានី/ខេត្ត ដើម្បីឲ្យអនុវត្តស្របទៅតាមច្បាប់ និងបទបញ្ជានីតិវិធីបោះឆ្នោតក៏ដោយ គ.ជ.ប ហាក់ដូចជាខ្វះអំណាចក្នុងការអនុវត្ត និងមិនធ្វើការព្រមានចំពោះការប្រព្រឹត្តិល្មើសពីសំណាក់អាជ្ញាធរ ដូចជាករណីអាជ្ញាធរគណបក្សប្រជាជនកម្ពុជានៃសាលារាជធានីភ្នំពេញមិនបើកទីលានប្រជាធិបតេយ្យឲ្យគណបក្សនយោបាយប្រើប្រាស់សម្រាប់ការឃោសនាបោះឆ្នោត។

ជាការពិតការឃោសនាបោះឆ្នោតនេះមិនមានអ្វីទាក់ទាញប្រជាពលរដ្ឋទូទៅ។ ទោះបីយ៉ាងនេះក្តី មកដល់ពេលនេះ គណបក្សសង្គ្រោះ បានធ្វើសកម្មភាពឃោសនារបស់ខ្លួនដោយមានការហែក្បួននៅតាមទីសាធារណៈស្ទើរតែគ្រប់រាជធានី/ខេត្ត។ បើពិនិត្យជារួមសកម្មភាពឃោសនាទាំងអស់នោះហាក់ដូចជាដំណើរការធម្មតាដោយគ្មានការរំខានអ្វីនោះទេ លើកលែងតែសកម្មភាពឃោសនានៅខេត្តកំពង់ចាមកាលពីថ្ងទី០៤ ឧសភា ២០១៤ ដែលគេសង្កេតឃើញមានការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធនៅក្បែរទីតាំងដែលគណ បក្សសង្គ្រោះជាតិរៀបចំការឃោសនា ក្នុងចេតនាគំរាមកំហែងដល់ប្រជាពលរដ្ឋដែលចូលរួមក្នុងការឃោសនា។ ចំណែកឯសារនយោបាយសម្រាប់ការឃោសនាបោះឆ្នោតនេះ ថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិបានលើកឡើងពីបញ្ហាសង្គមដែលកំពុងកើតមាននាពេលបច្ចុប្បន្ន ព្រមទាំងរិះគន់ចំពោះការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាច។ ប្រជាពលរដ្ឋដែល ចូលរួមក្នុងការឃោសនាហាក់ដូចជាមិនសូវយល់ដឹងពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានេះទេ ពួកគេចូលរួមដើម្បីទាមទារឲ្យមានការផ្លាស់ប្តូរថ្នាក់ដឹកនាំប្រទេសកំពូលទៅវិញ នេះបើតាមការផ្សាយរបស់វិទ្យុអាស៊ីសេរីកាលពីថ្ងៃទី០៧ ខែឧសភា ២០១៤។

មួយវិញទៀតមានការជ្រៀតជ្រែកខាងនយោបាយពីរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជាក្នុងការបញ្ឈប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិរបស់គណបក្សប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ។ក្រសួងមហាផ្ទៃ នៅថ្ងៃទី ២០ មីនា ឆ្នាំ ២០១៤ បានចេញលិខិតស្តីពីការអនុវត្តន៍គោលការណ៍ និងនីតិវិធីចំពោះ សមាជិកក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌដែលបានទៅឈរឈ្មោះជាបេក្ខជនពេញសិទ្ធិ ឬបេក្ខជនបម្រុងសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ លើកទី២។ ផ្អែកលើមាត្រា១៥ និង១៦ នៃច្បាប់ស្តីពីគណបក្សនយោបាយដែលបានចែងថា ប្រជាពលរដ្ឋខ្មែរម្នាក់ មិនអាចជាសមាជិកគណបក្សនយោ បាយលើសពីមួយក្នុងពេលតែមួយបានទេ។ ក្នុងករណីដែលបុគ្គលមួយរួមចូលរួមជាសមាជិកគណបក្សនានាយ៉ាងច្រើន សមាជិកភាពក្នុងគណបក្សនយោបាយចុងក្រោយត្រូវចាត់ទុកជាបានការ។ សមាជិកគណបក្សនយោបាយត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងករណីបានលាឈប់ ឬបានបោះបង់សមាជិកភាពនៃគណបក្សនយោបាយរបស់ខ្លួន និងផ្អែកលើមាត្រា២២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការបាត់បង់សមាជិកភាពពីគណបក្សនយោបាយ នឹងនាំឲ្យសាមីខ្លួនបាត់បង់សមាជិកភាពពីសមាជិកក្រុមប្រឹក្សា ក្រសួងមហាផ្ទៃបានណែនាំឲ្យក្រុមប្រឹក្សារាជធានី/ខេត្ត និង ក្រុង/

ស្រុក/ខណ្ឌត្រូវចាត់វិធានការចាត់ចែងអនុវត្តមាត្រា២៣នៃ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឲ្យជ្រើសរើសបេក្ខជន មកជំនួសបេក្ខជនក្រុមប្រឹក្សាដែលបានឈរឈ្មោះជាបេក្ខជនបោះឆ្នោតឲ្យ គណបក្សសង្គ្រោះជាតិ ហើយណែនាំឲ្យចាត់វិធានការគ្រប់គ្រងការបើក ប្រាក់ឧបត្ថម្ភចំពោះពួកគេ។

ការយកមាត្រាច្បាប់ខាងលើមកប្រើប្រាស់ដើម្បីដក សមាជិកភាពក្រុមប្រឹក្សាមកពីគណបក្សមួយ ក្នុងពេលដែល សមាជិកក្រុមប្រឹក្សានោះបាន ចុះបញ្ជីបេក្ខជនឈរឈ្មោះ បោះឆ្នោតសម្រាប់គណបក្សផ្សេង នៅពេលមានការរៀបចំ ការបោះឆ្នោត រារាំងលើការអនុវត្តន៍សិទ្ធិសេរីភាពផ្នែក នយោបាយរបស់ប្រជាពលរដ្ឋដែលបានការពារក្នុងរដ្ឋធម្មនុញ្ញ ត្រង់មាត្រាកថាខណ្ឌទី១មាត្រា៣៤ថ្មី បានចែងថា ប្រជាពលរដ្ឋទាំងពីរភេទអាចឈរឈ្មោះឲ្យគេបោះឆ្នោត ហើយ រំលោភច្បាប់រដ្ឋធម្មនុញ្ញ កថាខណ្ឌទី១ មាត្រា៣៥ ប្រជាពលរដ្ឋ ទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ។ តាមធម្មតាប្រជាពលរដ្ឋដែលសកម្មក្នុងជីវភាពនយោបាយតែងតែធ្វើការសម្រេចចិត្តក្នុងការចូលរួម បម្រើគោលនយោបាយរបស់គណបក្សណាមួយដែល ខ្លួនពេញចិត្ត ដូចនេះពួកគេត្រូវតែបានផ្តល់សិទ្ធិពេញលេញក្នុងការផ្លាស់ប្តូរសមាជិកភាពនៃគណបក្សនយោ បាយណាមួយ ដោយគ្មានលក្ខខណ្ឌ។





ការប្រមូលផ្តុំគណបក្សប្រជាជនកម្ពុជា ក្នុងការឃោសនាបោះឆ្នោតជាតិ នីតិកាលទី៥ ឆ្នាំ ២០១៣ (ថ្ងៃ២៦ កក្កដា ឆ្នាំ២០១៣៖រូបថតពី Thomas Cristofoletti Ruom 2013)

ស្មារតីសំខាន់នៃមាត្រា១៥ និង ១៦ នៃច្បាប់ស្តីពីគណបក្សនយោបាយខាងលើ និងស្មារតីនៃមាត្រា២២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានន័យផ្តល់ អំណាចដល់គណបក្សនយោបាយក្នុងការផ្លាស់ប្តូរសមាជិកមន្ត្រីជាប់ឆ្នោតរបស់គណបក្សខ្លួន ក្រោយពេលមន្ត្រីរបស់ខ្លួនណាម្នាក់បាត់បង់សមាជិកភាពក្នុងបក្សនយោបាយដែលជាប់ឆ្នោតនោះ ព្រោះគណបក្សនយោបាយតែងមានការបារម្ភមន្ត្រីជាប់ឆ្នោតរបស់ខ្លួនចុះចូលជាមួយគណបក្សនយោបាយផ្សេង។ បទបញ្ញត្តិនៃមាត្រានេះ មិនបានផ្តល់សិទ្ធិអំណាចដល់ស្ថាប័នរដ្ឋណាមួយ ដើម្បីគ្រប់គ្រងការផ្លាស់ប្តូរសមាជិកភាពរបស់មន្ត្រីជាប់ឆ្នោតរបស់គណបក្សណាមួយឡើយ។ ប្រសិនបើសាមីគណបក្សនយោបាយដែលជាប់ឆ្នោតមិនស្នើឲ្យមានការផ្លាស់ (ត)

ប្តូរសមាជិកភាពនេះទេ មន្ត្រីទទួលបានអាណត្តិសាធារណៈនោះនៅតែបន្តដំណែងរបស់ខ្លួនរហូតដល់បញ្ចប់អាណត្តិតាមច្បាប់កំណត់។ បើទោះបីជាច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌ ក៏មិនបានចែងឲ្យច្បាស់លាស់ពីការផ្អាក ឬដកដំណែងសមាជិកក្រុមប្រឹក្សានៅចន្លោះពេលអន្តរកាលបោះឆ្នោតនេះ ស្មារតីនៃការអនុវត្តន៍នាពេលអន្តរកាលបោះឆ្នោតឆ្នាំ២០១៣ ក្នុងកិច្ចជំនួបថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជា ជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី១៦ ខែកញ្ញា ២០១៣ គណៈប្រតិភូគណបក្សប្រជាជនកម្ពុជាយល់ថាត្រូវផ្តល់ប្រាក់បៀវត្ស៍ជូន តំណាងរាស្ត្រ២៩មកពីគណបក្សសមរង្ស៊ី និង គណបក្សសិទ្ធិមនុស្សវិញ។ តំណាងរាស្ត្រទាំង២៩រូប មិនបានបាត់បង់សមាជិកភាពរដ្ឋសភារបស់ខ្លួនឡើយ បើទោះបីជាពួកគេបានក្លាយជាសមាជិកភាពនៃគណបក្សគណបក្សសង្គ្រោះជាតិដែលពេលនោះមិនទាន់មានអាសនៈក្នុងរដ្ឋសភាព និងត្រូវបានសភាគណបក្សប្រជាជនកម្ពុជាអនុម័តបង្អកប្រាក់បៀវត្ស៍។ ការមិនបាត់បង់សមាជិកសភានៃតំណាងរាស្ត្រទាំង២៩រូបនាពេលនោះគឺយោងតាមមាត្រា៩៥ នៃរដ្ឋធម្មនុញ្ញ និងមាត្រា១២០ថ្មី កថាខ័ណ្ឌទី២ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា សមាជិកភាពសភាអាចត្រូវបានជំនួសតែក្នុងរយៈ ពេលមុន០៦ខែមុនចប់នីតិកាល។ សមាជិកក្រុមប្រឹក្សារាជធានី/ខេត្ត និងក្រុង/ស្រុក/ខណ្ឌក៏ជាមន្ត្រីទទួលបាន អាណត្តិសាធារណៈផងដែរ។ការប្រើប្រាស់មាត្រា១៥ នៃច្បាប់ស្តីពីគណ បក្សនយោបាយដោយរាជរដ្ឋាភិបាលគណបក្សប្រជាជនកម្ពុជា គឺមានចេតនាជ្រៀតជ្រែកខាងនយោបាយបង្កការលំបាកដល់គណបក្សនយោបាយផ្សេងទៀតដែលចូលរួមប្រកួតប្រជែងបោះឆ្នោត។

ទោះបីជាបរិយាកាសមុនថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត ក្រុង/ស្រុកខណ្ឌមិនមានអំពើហិង្សា ឬការគំរាមកំហែងក៏ដោយ ប៉ុន្តែអាជ្ញាធរនៃគណបក្សប្រជាជនកម្ពុជាបានរំលោភអំណាច ហើយរាជរដ្ឋាភិបាលនៃគណបក្សប្រជាជនកម្ពុជាបានជ្រៀតជ្រែកដែនសមត្ថកិច្ចរបស់ គ.ជ.ប ដោយបំពានច្បាប់ និងបង្កការលំបាកដល់គណបក្សដែលចូលរួមប្រកួតប្រជែកសម្រាប់ការបោះឆ្នោតនេះ។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

| | | |
|---|---|---|
| ១. លោក **សៀន ប៊ុនរិទ្ធ** | មន្ត្រីផ្នែកអង្កេតខុមហ្វ្រែល | ទូរស័ព្ទ៖ ០៨៩ ២១ ២១ ១០ |
| ២. លោក **សួន យុធ្យា** | មន្ត្រីផ្នែកតស៊ូមតិខុមហ្វ្រែល | ទូរស័ព្ទ៖ ០៨៨ ៨ ១៤២ ៧៨៣ |





ការប្រមូលផ្តុំគណបក្សសង្គ្រោះជាតិក្នុងយុទ្ធនាការឃោសនាបោះឆ្នោតជាតិឆ្នាំ២០១៤ នៅទីលានប្រជាធិបតេយ្យ និងវត្តភ្នំ (ថ្ងៃ២៦ កក្កដា ឆ្នាំ២០១៣៖រូបថតពី Thomas Cristofoletti Ruom 2013)



## យុវជនល្អ

និពន្ធដោយ មេធាវី សុគ សំអឿន

បទពាក្យ៧

យុវជនប្រៀបដូចជាទំពាំង សម្រិតសម្រាំងជួសឫស្សី
ពេលឫស្សីចាស់អស់រាសី គឺទំពាំងថ្មីអ្នកជំនួស ។
បើទៅជំនួសក្រិនតូចទាប មិនអាចប្រៀបធៀបអ្នកត្រូវជួស
ធ្វើម្តេចនិងជ្រោងពូជឲ្យខ្ពស់ ជាតិនឹងមានគ្រោះវងឱនអាប់។
ដូចនេះត្រូវត្រៀមខ្លួនជាស្រេច មិនត្រូវធ្វេសភ្លេចចាំគេប្រាប់
រឿងអ្វីមិនល្អនាំពូជអាប់ មិនត្រូវត្រងត្រាប់ចៀសឲ្យឆ្ងាយ។
ធ្វើអ្វីក៏ដោយកុំឲ្យឆ្គួត ទោះឱនទោះអួតគិតវែងឆ្ងាយ
ឆ្គួតគឺវក់ពេកមិនបេះស្តាយ ទោះឆ្គួតសប្បាយក៏មិនល្អ ។
អ្នកខ្លះពោលថាចង់ពិសោធន៍ ខ្លាចគេថាឆោតមិនដឹងល្អ
ចង់ភ្លក់ស្រាស្រីថ្នាំងក់ក លុះភ្នែកឡើងសទើបដឹងប្រាណ។
ដូចគេប្រាប់ថាពស់ចឹកស្លាប់ កូនអើយចូរស្តាប់ណាកល្យាណ
បើហ៊ានលូកលេងនឹងស្លាប់បាន តើប្រុសកល្យាណសាកឬទេ ។
ដូចនេះបើល្បែងណាគ្រោះថ្នាក់ មានគេប្រាប់ដាក់កុំលលេ
កុំសាកលង់ប្រាណនាំបង់កេរ្តិ៍ ត្រូវចះរិះរេរកផ្លូវល្អ ។
បើសិនមានពេលស្វែងរៀនវិញ ស្រាវជ្រាវទន្ទេញសិល្ប៍អក្សរ
ស្វែងស្ម័គ្រការងារទើបវាល្អ ងាយរករបរនាអនា ។
ចូរស្វែងចំណេះទាន់នៅក្មេង កុំគិតតែលេងគ្មានបានការ
ស្វែងបទពិសោធន៍រៀនភាសា ក្រោយងាយរកការធ្វើបានល្អ ។
រីឫស្សីចាស់ក៏ដូច្នោះ ត្រូវបើកប្រឡោះបើកលំហរ
អាចមានសេរីដុះដាលល្អ ទំពាំងអាចចរប្រសើរបាន ។
សង្ឃឹមថាប្អូនអាចត្រងត្រាប់ យកជាតម្រាប់សាងខ្លួនប្រាណ
ជាទំពាំងថ្មីស្អាតស្អំបាន នគរថ្កើងថ្កានល្បីរន្ទឺ ។

សសេរនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ និង
កែសម្រួល ថ្ងៃទី ១ ខែធ្នូ ២០១៣

## គណៈកម្មការ ព្រឹត្តបត្រ អ្នកឃ្លាំមើល

១. លោក **គល់ បញ្ញា** ទីប្រឹក្សាយោបល់

២. លោក **សួន យុធា** ទីប្រឹក្សាច្បាប់

៣. លោក **សួន សឿន** ទីប្រឹក្សាបច្ចេកទេស

៤. កញ្ញា **គោគ ស្រីពេជ្រ** រចនាព្រឹត្តិបត្រ និងការផ្សាយ

៥. លោក **នាង សុវណ្ណ** លេខាអ្នកនិពន្ធ និងថតរូប

៦. លោក **ស៊ិន ឪត្យសីហា** លេខាអ្នកនិពន្ធ និងថតរូប

៧. លោក **មាស សេរីសោភណ្ឌ** លេខាអ្នកនិពន្ធ និងថតរូប

## សេចក្តីជូនដំណឹង

ព្រឹត្តិបត្រ **អ្នកឃ្លាំមើល** ផលិតឡើង ដើម្បីបំពេញចន្លោះព័ត៌មានរវាងប្រជាពលរដ្ឋជាម្ចាស់ឆ្នោត និងអ្នកតំណាងរាស្ត្រ អ្នកដឹកនាំ ដែលពាក់ព័ន្ធនឹងការចូលរួមស្ថាបនា និងអភិវឌ្ឍន៍សង្គមប្រជាធិបតេយ្យនៅកម្ពុជា។

ប្រសិនបើលោក អ្នកនាង កញ្ញា មានសំណូមពរ ឬបំណងចូលរួមយោបល់ ឬស្នើសុំព្រឹត្តិបត្រ និងឯកសារផ្សេងៗដែលផលិតឡើងដោយខុមហ្វ្រែល សម្រាប់រក្សាទុក ឬសិក្សាស្រាវជ្រាវ សូមទំនាក់ទំនងមកការិយាល័យខុមហ្វ្រែល ឬចូលទៅកាន់បណ្តាញផ្សព្វផ្សាយសង្គម របស់ខុមហ្វ្រែល មានដូចជា គេហទំព័រ (www.comfrel.org) ហ្វេសប៊ុក ប្លុក ឬអាស័យដ្ឋានដូចបាន ផ្តល់ជូននេះ យើងខ្ញុំនឹងដោះស្រាយជូនរាល់បញ្ហារបស់លោក អ្នកនាង កញ្ញា ដោយមេត្រីភាព។

សូមអរគុណ !

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា

គេហទំព័រផ្លូវការ
www.comfrel.org

#១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

Phone: (855)23-884-150 Fax: (855)23-885-745 / E-mail: comfrel@online.com.kh


វេទិកា សួរអ្នកតំណាង
ASK YOUR MP
•Facebook: www.facebook.com/comfrel.org/app_156218351098324
•Website: www.cambodianvotervoice.org/kh/SOURSAKPHEA.html
•SMS: 010 53 53 54 or 017 610 351
•Voice Call: 010/015 802 777 012 410 100/088 333 2100
•Email:SOURSAKPHEA@online.com.kh
សំណួរផ្ញើទៅកាន់វេទិកា
Questions sent to platform
Email
សំណួរផ្ញើទៅកាន់អ្នកតំណាង
Questions sent to MPs
SMS
វេទិកា
ASK YOUR MP: CAMBODIA
Platform
ប្រជាពលរដ្ឋ
Citizen
អ្នកតំណាង (តំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា & បេក្ខជនជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ)
MPs (CPP MPs & CNRP Elected Candidates)
SMS
Email
ចម្លើយផ្ញើទៅកាន់ប្រជាពលរដ្ឋ
Answer sent to citizen
Radio Program
Email
ចម្លើយផ្ញើទៅកាន់វេទិកា
Answer sent to platform
SMS
រៀងរាល់ថ្ងៃច័ន្ទ នៃសប្តាហ៍ទីពីរ
Mondays of the second week
7:30-8:30am on FM 105 MHz